# ភាពកុះករនៅក្នុងបរិវេណអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃ មិនបញ្ចប់កិច្ចពិភាក្សាដេញដោល

ប្រែសម្រួលដោយ នង ច័ន្ទមល្លិកា

ទិដ្ឋភាពនាពេលព្រឹកនេះមានសភាពកុះករ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ ខណៈពេលដែលដំណើរការនីតិវិធីក្នុងករណីសំណុំរឿង០០២/០១ កំពុងត្រូវបានរៀបចំ ឲ្យធ្វើការបញ្ចប់ការសួរដេញដោលនៅថ្ងៃបិទបញ្ចប់ ។ សវនាការចាប់ផ្តើមនៅវេលាម៉ោង៩ព្រឹក លោកប្រធានអង្គជំនុំជម្រះ និល ណុន ផ្តល់វេទិកាបកស្រាយដល់ សហមេធាវីការពារក្តី នួន ជា ។ ដោយសារតែមានការទាមទារឲ្យបកស្រាយផ្ទាល់ ជាជាងការបកស្រាយតាមប្រព័ន្ធអេឡិចត្រូនិកភ្ជាប់ពីបន្ទប់ឃុំខ្លួន នៅថ្ងៃនេះ នួន ជា បុរសវ័យចំណាស់ដែលមានអាយុ ប្រហែល៨៧ឆ្នាំរូបនេះ បានមកកាន់បន្ទប់សវនាការផ្ទាល់ ដើម្បីធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលផ្នែកសំណុំរឿង០០២/០១ ចុងក្រោយបង្អស់ជាប្រវត្តិសាស្រ្ត ។

## នួន ជា ប្រកាសថាខ្លួនគ្មានទោសកំហុស

មិនទាន់បានពីរនាទីផង បន្ទាប់ពី មនុស្សកុះករតម្រង់ជួរទៅកាន់បន្ទប់សវនាការ និងបន្ទប់សារព័ត៌មានដើម្បីតាមដានដំណើរការកាត់ក្តី នួន ជា បានពោលខ្លាំងៗថា «តាមរយៈសវនាការនេះ បានបញ្ជាក់ប្រាប់យ៉ាងច្បាស់ថា ខ្ញុំមិនមានការជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសដូចលោក លោកស្រីសហព្រះរាជអាជ្ញាបានចោទប្រកាន់នោះទេ ។ និយាយឲ្យខ្លីទៅ ខ្ញុំមិនមានទោសអ្វីទាក់ទងទៅនឹងការចោទប្រកាន់ដូចបានលើកឡើងនោះទេ» ។

បន្ទាប់មក លោក នួន ជា ចំណាយពេលប្រហែលជាជិតមួយម៉ោង ដើម្បីធ្វើការបកស្រាយក្នុងតុលាការ មុននឹងដល់ពេលវេលាសម្រាករបស់គាត់ ដែលត្រូវនឹងការស្នើសុំយោងតាមបញ្ហាសុខភាពរបស់គាត់ ។ គាត់ចាប់ផ្តើមបកស្រាយទាំងកំហឹងលើដំណើរការនីតិវិធីតុលាការជុំវិញការកាត់ក្តីលើរូបគាត់ ។ គាត់លើកឡើងថា តាមផ្លូវច្បាប់ គោលបំណងនៃការបង្កើតតុលាការនេះឡើង គឺមានទិសដៅស្វែងរកការពិត និងយុត្តធម៌ គឺអាស្រ័យលើភស្តុតាងរឹងមាំ ស្របច្បាប់ និងជឿទុកចិត្តបាន ដូច្នេះ អ្វីដែលគាត់លើកឡើងអំពីយុត្តិធម៌ក្នុងការរួចពីទុក្ខទោសនោះគឺ «លោក លោកស្រីសហព្រះរាជអាជ្ញា នៅតែមិនអាចរកបាន នូវភស្តុតាងច្បាស់លាស់ ដើម្បីបំពេញធាតុផ្សំបទល្មើស ដែលចោទប្រកាន់ដាក់បន្ទុកមកលើរូបខ្ញុំបាននោះទេ» ។ លើសពីនេះទៀត គាត់សំអាងថា ការដោះលែងរូបគាត់

នេះ ដោយសារតែការពិតត្រូវបានបង្ហាញដូច “សិទ្ធិស្របច្បាប់របស់ខ្ញុំមួយចំនួន ក៏មិនបានធានាត្រឹមត្រូវនៅក្នុងតុលាការនេះផងដែរ ដូចជាសិទ្ធិទទួលបានការកាត់សេចក្តីឲ្យបានឆាប់រហ័ស សិទ្ធិទទួលបានការការពារ តាមផ្លូវច្បាប់ សិទ្ធទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ និងសិទ្ធិផ្សេងៗទៀត ដែលធានាដោយ ច្បាប់ជាតិ និងអន្តរជាតិ” ។

ក្នុងរយៈពេល៤៥នាទី បន្ទាប់មកទៀត នួន ជា នឹងរៀបរាប់ពីតួនាទី និងសកម្មភាពរបស់គាត់ក្នុងបក្សកុម្មុយនិស្តកម្ពុជា ជាពិសេសកំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ គាត់រៀបរាប់ថាគោលដៅរបស់បក្សគឺ “រូបខ្ញុំផ្ទាល់សូមបញ្ជាក់នូវចំណុចសំខាន់ៗមួយចំនួនទៀត សម្រាប់ជាមូលដ្ឋានផ្តល់ជូនលោក លោកស្រីចៅក្រមឲ្យបានកាន់តែជ្រាបច្បាស់ អំពីភាពគ្មានទោស និងសុចរិតភាពរបស់ខ្ញុំពាក់ព័ន្ធនឹងបទចោទប្រកាន់ខាងលើ” ។ បន្ថែមពីលើនេះថា “អ្វីដែលខ្ញុំនិយាយគឺសុទ្ធតែជាការពិត” នួន ជា និយាយ ដោយសំអាងលើហេតុផលដូចតទៅ៖

- គាតមិនមានអំណាចអ្វី និងមិនមានការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិបទល្មើស ដែលកើតមានឡើងនៅក្នុងរបបប្រជាធិបតេយ្យនោះទេ ។ សូមបញ្ជាក់ប្រាប់ថា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តួនាទីចំបងរបស់គាត់ដែលជាអនុលេខាបក្សគឺ ឃោសនាអប់រំអំពីគោលនយោបាយនៅក្នុងជួរសមាជិកបក្ស ។ គាត់និយាយថា “ខ្ញុំមិនដែលឃោសនាអប់រំឲ្យសមាជិកបក្សប្រព្រឹត្តអំពើអាក្រក់ ដូចជា ប្រើអំណាចអាជ្ញា ឬមានអាកប្បកិរិយាមិនល្អចំពោះប្រជាជននោះទេ” ។ បន្ថែមទៀត “ផ្ទុយទៅវិញ ខ្ញុំបានអប់រំឲ្យសមាជិកបក្សកុម្មុយនីស្តកម្ពុជាចេះគោរពស្រលាញ់ប្រជាជន បម្រើប្រជាជន និងប្រទេសជាតិរបស់ខ្លួន ។ ខ្ញុំមិនដែលអប់រំ ឬណែនាំសមាជិកបក្សកុម្មុយនីស្តកម្ពុជាណាម្នាក់ ឲ្យធ្វើបាប កាប់សម្លាប់បង្អត់អាហារប្រជាជន ឬប្រល័យពូជសាសន៍មួងណាទេ ។ ខ្ញុំតែងតែលើកយកគោល ការណ៍សំខាន់ៗរបស់បក្សកុម្មុយនីស្តកម្មុជា មកបង្រៀន និងអប់រំ ដល់សមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ក្នុងទិសដៅធ្វើយ៉ាងណាឲ្យសមាជិកបក្ស និងកងទ័ពប្រជាជនកម្ពុជាបដិវត្តន៍ទាំងអស់ ឲ្យអនុវត្តការងារ និងបម្រើប្រជាជនឲ្យបានល្អប្រសើរ” ។ បន្ទាប់មក គាត់បានលើកយក គោលការណ៍ដែលមានចែងនៅក្នុងមាត្រា២ នៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្នុងនោះរៀបរាប់ថា “ខ្ញុំតែងតែអប់រំឲ្យសមាជិកបក្សទាំងអស់ កុំឲ្យប្រើអំណាចអាជ្ញា កុំស្រី កុំស្រា កុំពុករលួយ កុំលេងល្បែងស៊ីសង ជាពិសេសឲ្យចេះសាមគ្គីគ្នាទាំងក្នុងជួរបក្ស និងមហាជន ។ និងបណ្តុះពុទ្ធិឲ្យសមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាត្រូវមានឆន្ទះស្នេហាជាតិ (អត់ទោស) ការពារជាតិ និងស្រលាញ់ប្រជាជន មានសាមគ្គីភាពផ្ទៃក្នុងល្អក្នុងទិសដៅការពារ និងកសាងប្រទេសជាតិមួយឲ្យបាន រីកចម្រើនរុងរឿង

និងឯករាជ្យឲ្យពិតប្រាកដ ហើយមិនអនុញ្ញាតឲ្យប្រទេសណាមួយ ធំក្តី តូចក្តី ជិតក្តី ឆ្ងាយក្តី ឈ្លានពាន និងធ្វើអាណានិគមមកលើប្រទេសកម្ពុជាបានជាដាច់ខាត» ។ គាត់បន្តនិយាយអំពីភាពចំបាច់ អំពើល្អ កាតព្វកិច្ច ដើម្បីរក្សាការពារទឹកដីរបស់ខ្លួន ដោយការ «កំទេច» ខ្មាំងសត្រូវ ការពង្រឹងសន្តិសុខ ស្ថិរភាពនយោបាយផ្ទៃក្នុង «ត្រូវអនុវត្តឲ្យបានល្អប្រសើរ ទើបបដិវត្តន៍មានការរីក ចម្រើនរុងរឿង» ។

- នួន ជា ក្នុងឋានៈជាអនុប្រធានគណៈកម្មាធិការទនាក់ទំនងចលនាកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា មានតួនាទីកសាងទំនាក់ទំនងជាមួយនឹងបក្សកុម្មុយនីស្តក្នុងប្រទេសវៀតណាម ដោយសារតែលោកប្រធានបក្ស ប៉ុល ពត មានកិច្ចការរវល់ច្រើន ។ «ខ្ញុំបានចូលរួមនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៥០» នេះជាសម្តីរបស់ នួន ជា ។ ពេលនោះ គឺមានវត្តមានកងទ័ពវៀតណាម (វៀតកុង) និងប្រជាជនសាមញ្ញ នៅក្នុងប្រទេសកម្ពុជារួចស្រេចទៅហើយ ហើយគាត់ពោលថា «ចាប់តាំងពីពេលនោះមក ខ្ញុំបានដឹងពីល្បិចកល និងកិច្ចការសម្ងាត់ជាច្រើនរបស់ប្រទេសវៀតណាម ដែលមានមកលើប្រទេសកម្ពុជាយើង» ។
- នួន ជា សហការណ៍ជាមួយក្រុមអ្នកបង្កើតបក្សកុម្មុយនីស្តឯករាជ្យដំបូងគេ របស់ប្រទេសវៀតណាម ។ នួន ជា បានលើកឡើងថា នៅដើមឆ្នាំ១៩៦៤ ប៉ុល ពត បានរំដោះបក្សចេញពីបក្សកុម្មុយនីស្តវៀតណាមទាំងស្រុង ហើយសមាជិកគណៈមជ្ឈិមមួយចំនួន បានទៅកសាងមូលដ្ឋានបង្អែករបស់ខ្លួនដែលមាន ឈ្មោះថា មន្ទីរ១០០ ដែលក្រោយមកមន្ទីរនេះបានចល័តទៅនៅខេត្តរតនគិរី ។ វៀតណាមបានខិតខំរកគ្រប់វិធីដើម្បីក្តោបក្តាប់បក្សកុម្មុយនីស្តកម្ពុជាគ្រប់ពេលវេលាទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងយោធា ។ នួន ជា រំឭកថា ក្នុងឆ្នាំ១៩៧០ ចលនាបក្សកុម្មុយនីស្តកម្ពុជាបានរីកដុះដាលយ៉ាងរហ័ស បន្ទាប់ពីមានការទម្លាក់ សម្តេចព្រះបាទ នរោត្តម សីហនុ ចេញពីតំណែងនៅថ្ងៃទី១៨ ខែមិនា ហើយបន្ទាប់មកចលនាកងទ័ពប្រជាជនដិវត្តន៍កម្ពុជា ក្រោមមកស្គាល់ថាជា «ខ្មែរក្រហម» ក៏បានរីកដុះដាលផងដែរ ។ នៅខណៈពេលនោះដែរ ប្រជាជនខ្មែរប្រមាណជា ៣០០០នាក់ត្រូវបានបញ្ជូនទៅវៀតណាមខាងជើងឲ្យទៅរៀនសូត្រ ទទួលការបំពាក់បំប៉ន ទាំងផ្នែកបច្ចេកទេស នយោបាយ និងសតិអារម្មណ៍នៅទីនោះ ។ នៅពេលដែលពួកគេត្រលប់មកវិញនៅពាក់កណ្តាលឆ្នាំ១៩៧៣ អ្នកទាំងនោះត្រូវបានចាត់តាំងឲ្យបម្រើការងារនៅក្នុងជួរបក្សនិងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ។ គាត់និយាយថា នេះជាចលនាចុងក្រោយដែលបញ្ឈាក់ពីល្បិចកលរបស់វៀតណាម ព្យាយាមគ្រប់គ្រងបក្សកុម្មុយនីស្តកមជា ។ ទោះជាយ៉ាងនេះក្តី គាត់ហ៊ាននិយាយថា បក្សកុម្មុយនីស្តកម្ពុជាដែលស្ថិតនៅក្រោមការដឹកនាំរបស់ ប៉ុល ពត

បានអនុវត្តនូវគោលការណ៍ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនជាអ្នកសម្រេចលើជោគវាសនា ជាតិដោយខ្លួនឯង» ។

មេធាវីការពារក្តីបន្តលើកឡើង ចំពោះកលល្បិចស៊ីជម្រៅរបស់វៀតណាម ប៉ុន្តែដូចជា មេដឹកនាំបក្សកុម្មុយនីស្តរូបនេះមិនដឹងពីអ្វីឡើយ ។ បន្ទាប់មកទៀត នួន ជា ប្រាប់ថា បក្សកុម្មុយនីស្តកម្ពុជាបានរកឃើញថា វៀតណាមបានបង្កប់ភ្នាក់ងាររបស់គេនៅក្នុងជួរបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ក្នុងគោលបំណងដើម្បីបំផ្លិចបំផ្លាញ បដិវត្តន៍កម្ពុជា សម្លាប់ប្រជាជន និងលេបយកទឹកដីនៃប្រទេសកម្ពុជា ដែលវៀតណាមមានមហិច្ឆិតាជាយូរមកហើយ ។ ជម្លោះរវាងកម្ពុជា និងវៀតណាមបានបន្ត ហើយបានរីកដុះដាលពេលក្រោយ ដែលចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១ វៀតណាមបានគ្រប់គ្រងប្រទេសទាំងមូល ហើយបញ្ចប់នៅពេលដែលប្រទេសកម្ពុជាមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។

## ជាការពិតទេដែលថាកំហុសអាស្រ័យលើវៀតណាម

យោងតាមពាក្យសម្តីរបស់ នួន ជា ទំនងជាបញ្ចុះបញ្ចូលឲ្យតុលាការជឿថា “ការបង្អត់អាហារដល់ប្រជាជាន ការសម្លាប់អ្នកទាំងនោះ វាជួយគ្នាទាំងស្រុងទៅនឹងហេតុផល និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា» ហើយសំអាងលើហេតុផលនេះ “សកម្មភាពដូចដែលបានរៀបរាប់ខាងលើគឺពិតជាវៀតណាមជាអ្នកប្រព្រឹត្តិមែន ។ បក្សកុម្មុយនីស្តកម្ពុជាបានទទួលរងការឈឺចាប់ នៅពេលដែលដឹងថា ពួកគេត្រូវបានចាញ់ល្បិចកលវៀតណាម ដែលធ្វើឲ្យប្រជាពលរដ្ឋខ្លួនស្លាប់ ហើយប្រទេសជាតិធ្លាក់ចូលទៅក្នុងភាពអន្តរាយ» នេះជាសម្តីរបស់ នួន ជា ។

នួន ជា បន្តបកស្រាយលើរឿងរ៉ាវដំបូងរបស់បក្សកុម្មុយនីស្តកម្ពុជា និងចំណងទាក់ទងរបស់បក្សនេះជាមួយនឹង កងទ័ពវៀតណាត (វៀតកុង) ។ ចំណងកិច្ចការទូតត្រូវបានកាត់ផ្តាច់នៅពេលដែលវៀតណាមឈ្លានពានប្រទេសកម្ពុជា ហើយការបញ្ជាកម្លាំងប្រយុទ្ធបានធ្លាក់ទាំងស្រុងទៅលើ សុន សេន ដែលជារដ្ឋមន្ត្រីក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ។ លោក នួន ជា បានប្រាប់ថា ជាធម្មតាគាត់ទទួលខុសត្រូវក្នុងការអនុម័តច្បាប់ គាត់បន្តទៀតថា “ប្រទេសកម្ពុជាទើបតែបញ្ចប់សង្គ្រាម ហើយក៏មានសង្គ្រាមបន្តជាមួយវៀតណាមទៀតនោះ ក្នុងរយៈពេលខ្លីបែបនេះ យើងមនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើច្បាប់ជាច្រើននោះទេ ។ ម្យ៉ាងវិញទៀត ដោយសារប្រទេសជាតិស្ថិតក្នុងស្ថានភាពបែបនេះ កិច្ចការច្បាប់គមិនមែនជាកិច្ចការអាទិភាពនោះដែរ» ។

នួន ជា ធ្វើការពន្យល់ពីទ្រឹស្តីនៃរបបកុម្មុយនីស្ត និងការដឹកនាំប្រទេសនៃរបបកម្ពុជាប្រជាធិបតេយ្យថា “ក្នុងរបបកុម្មុយនីស្តមានបក្សដឹកនាំ និងរដ្ឋគ្រប់គ្រងប្រទេស» ។ តែអំណាចត្រូវបានចែក

ចេញជាបី គឺនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការ ដោយផ្អែកលើគោលការណ៍ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏វាគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ។ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការមិនបានដំណើរការពេញលេញទេ ជាក់ស្តែងមានតែនីតិប្រតិបត្តិទេដែលដំណើរការងារពេញលេញ ហើយ ប៉ុល ពត បានទទួលតំណែងជានាយករដ្ឋមន្ត្រី មានអំណាចជារួមក្នុងការដឹកនាំ និងគ្រប់គ្រងប្រទេស ទាំងនៅក្នុងជួរបក្ស និងនៅក្នុងរដ្ឋាភិបាល ។ នួន ជា សង្កត់ធ្ងន់ថា "គ្មាននរណាម្នាក់អាចជំនួសគាត់បានឡើយ ។ ផ្អែកលើមូលដ្ឋាននេះបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមានអំណាចអ្វីបន្តិចក្នុងការគ្រប់គ្រង និងប្រតិបត្តិការងារនៃនីតិប្រតិបត្តិឡើយ" ។

នួន ជា បដិសេធចំពោះការចោទប្រកាន់លើមុខតំណែងផ្សេងទៀតថា "ខ្ញុំមានចម្ងល់យ៉ាងខ្លាំងចំពោះការលើកឡើងរបស់លោក លោកស្រីសហព្រះរាជអាជ្ញាថា ខ្ញុំធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្តីទី ជាគណៈកម្មាធិការយោធាមជ្ឈិម និងមានការជាប់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមន្ទីរស-២១ ។ ការចោទប្រកាន់បែបនេះបើទោះមានចេតនា ឬអចេតនាក៏ដោយ វាជាការនិយាយខុសពីការពិតទាំងស្រុង ហើយពុំមានភស្តុតាងជាក់លាក់ផងដែរ" ។

នួន ជា ថែមទាំងបានបដិសេធចំពោះការចោទថា គាត់ជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិម បញ្ជាការលើកិច្ចការទាហាន ឬសន្តិសុខ ដោយរៀបរាប់ថា កិច្ចការទាំងអស់ សុន សេន ជាអ្នកគ្រប់គ្រងផ្ទាល់ ។ គាត់បន្ថែមថា "ខ្ញុំមិនដែលបានជួប មិនបានគ្រប់គ្រង ឬបញ្ជា ឌុច ឲ្យធ្វើបាប ឬសម្លាប់មនុស្សនោះទេ ។ អស់លោកគួរតែជ្រាបហើយ សារជាតិជាទាហាន ឬសន្តិសុខ គឺមិនដែលស្តាប់អ្នកណាក្រៅពីមេបញ្ជាការផ្ទាល់របស់ខ្លួននោះទេ ដូច្នេះគ្មានហេតុផលអ្វីដែល ឌុច ស្តាប់ខ្ញុំនោះទេ ។ ខ្ញុំទើបតែឮឈ្មោះ ឌុច នៅក្រោយឆ្នាំ១៩៧៩តែប៉ុណ្ណោះ" ។ គាត់បន្តបដិសេធលើអ្វីដែលឌុចបានចោទប្រកាន់មកលើរូបគាត់សំអាងថា អ្វីដែលឌុចចោទប្រកាន់ព្រោះចង់គេចពីការទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ នួន ជា លើកឡើងថា "ខ្ញុំមិនបានបំពេញកិច្ចការទាំងនេះទាល់តែសោះ ហើយក៏គ្មានឯកសារណាមួយជាក់លាក់បញ្ជាក់ពីរឿងនេះដែរ" ។

គោលបំណងរបស់គាត់ក្នុងការចូលរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះគឺ "មានបំណងចង់រំដោះប្រទេសជាតិពីអាណានិគមនិយម និងការពារទឹកដីពីការឈ្លានពានពីប្រទេសជិតខាងដែលពួកគេមានបំណងចង់លេបយកតាំងពីយូរយារណាស់មកហើយនោះ ។ ខ្ញុំស្រលាញ់ប្រជាជនខ្ញុំ ខ្ញុំមិនមានបំណង និងចេតនាណាមួយធ្វើបាប កាប់សម្លាប់ បប្រល័យពូជសាសន៍ឯងនោះទាល់តែសោះ" ។

បង្វែរមកលើការចោទប្រកាន់នៅឯទួលពោធិ៍ជ្រៃវិញ នួន ជា បញ្ជាក់ម្តងទៀតអំពីការគ្មានភស្តុតាងគ្រប់គ្រាន់នៅក្នុងបទចោទ ជាពិសេសគឺការសម្លាប់អតីតទាហាន លន់ នល់ ។ បន្តទៀត "តាមអ្វីខ្ញុំដឹង បក្សកុម្មុយនីស្តកម្ពុជាមិនដែលបានបង្កើតគោលនយោបាយឲ្យកងកម្លាំងរបស់ខ្លួនកាប់សម្លាប់

*អតីតទាហាន លន់ នល់ ឬប្រជាជនទេ ។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះឈ្លើយសឹក គឺសន្តោសប្រណី និងលើកលែងទោស ពីព្រោះអ្នកទាំងនោះត្រូវគេចាប់បង្ខំមកឲ្យធ្វើទាហាន ប្រសិនបើយើងសម្លាប់អ្នកទាំងនោះ ដូចការចោទប្រកាន់ គឺខុសពីមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា» ។ បន្ទាប់មកទៀត គាត់រំឭកដល់តុលាការអំពី ការផ្តល់សក្ខីកម្មដែលពោរពេញដោយចំណុចមន្ទិលសង្ស័យ និងសក្ខីកម្មផ្ទុយគ្នា លើចំនួនទាហាន លន់ នល់ ដែលត្រូវបានសម្លាប់ ចំនួនទ្បានដឹកអ្នកទាំងនោះ និងទិដ្ឋភាពអ្នកដែលបានលួចចូលទៅមើលនៅពេលនោះ ។ គាត់ចាត់ទុកថា ចម្លើយសាក្សីទាំងនោះមិនអាចឲ្យជឿ និងយកជាការបានទេ និងថា «ពោរពេញទៅដោយការភូតកុហក» ។ ក្រៅពីនេះ គាត់បន្ថែម « ខ្ញុំសួរថា នៅពេលនោះក្នុងនាមជាអ្នកដឹកនាំម្នាក់ តើមានពេលវេលាឯណាសម្រាប់គិតគូរពីបញ្ហានេះ?» ពួកគាត់ និងជនរួមជាតិទាំងអស់ មានកិច្ចការរួមសំខាន់ៗ និងបន្ទាន់ជាច្រើន គឺដោះស្រាយជីវភាពរបស់ប្រជាជន និងការពារជាតិឲ្យផុតពីការប៉ុនប៉ងគ្រប់គ្រងពីបក្សកុម្មុយនីស្តវៀតណាម និងពីគូបដិបក្ខ ។*

## យុទ្ធសាស្ត្រប្រយុទ្ធ ការស្តីបន្ទោស និងខ្លួនក្រពើ

*បន្ទាប់មកទៀត នួន ជា បានលើកយកព្រឹត្តិការណ៍នៃជ្រុងម្ខាងដែលធ្លាប់បានកើតឡើងមករៀបរាប់បន្តទៀត ដើម្បីលាតត្រដាងពី អំពើហិង្សាមកលើកសិករក្រីក្រ និងជនស្លូតត្រង់ នៅក្នុងខេត្តមួយក្នុងប្រទេសកម្ពុជា ។ លើសពីនេះទៀត សូមកុំភ្លេចថា មុនពេលសម្រេចចិត្តតស៊ូដោយអាវុធក្នុងបុព្វហេតុរំដោះប្រទេសជាតិ សមាជិកបក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនជាច្រើនរូបត្រូវបានគេលួចសម្លាប់ ចាប់ខ្លួន ធ្វើទារុណកម្មដោយគ្មានហេតុផល និងបាត់ខ្លួនជារៀងរាល់ថ្ងៃ ។ គាត់ក៏បានរំឭកពីអំពើហិង្សាដែលកើតឡើងក្នុងសម័យអាណានិគមនិយមបារាំងជាងរយៈពេលជិតមួយទសវត្ស ពួកអ្នកមានអំណាចតែងតែឈ្នះ ហើយ(ប្រជាកសិករស្លូតត្រង់ជាអ្នកចាញ់ជានិច) ។ គាត់លើកឡើងពីការចាប់រំលោភស្ត្រី ការសម្លាប់ប្រជាជន និងពួកទាហាន លន់ នល់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហរដ្ឋអាមេរិក និងព្រឹត្តិការណ៍ថ្មីៗនេះ ។ គាត់នៅតែមានការងឿងឆ្ងល់ថា ហេតុអ្វីបានជាទង្វើទាំងអស់នោះមិនត្រូវរាប់បញ្ចូលថាជា «អំពើប្រល័យពូជសាសន៍» ឬក៏ «បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ» ផងទៅ» ។ សូម្បីតែនៅក្នុងឆ្នាំ១៩៧៩ ពេលវៀតណាមបានចូលឈ្លានពាន និងកាន់កាប់ប្រទេសកម្ពុជា ហើយនៅឆ្នាំបន្តនៃការប្រយុទ្ធ (រួមមានការបាញ់ផ្លោងដាក់ជំរំជនភៀសខ្លួននៅតាមព្រំដែនកម្ពុជា-ថៃ) ធ្វើឲ្យបាត់បង់ជីវិតមនុស្សរាប់សិបនាក់ ។ «តើនេះមិនមែនជាផែនការសម្លាប់ប្រជាជនទេឬ?» នួន ជា បានចោទសួរ ។*

ពេលខ្លះ នន ជា នៅបន្តរក្សាគោលជំហរបស់ខ្លួនដើម្បីផ្សារភ្ជាប់នឹងការពិត និងអ្វីដែលបាន កើតឡើងជាប្រព័ន្ធដូច "ប្រសិនបើចាត់ទុកការកាប់សម្លាប់គ្នាក្នុងពេលធ្វើសង្គ្រាមថាជាផែនការធ្វើ ឡើងជាប្រព័ន្ធ ហេតុអ្វីមិនចោទប្រកាន់ទៅលើគូបដិបក្ខម្ខាងទៀតនៃសង្គ្រាមផងទៅ?" គាតបន្តទៀត ថា "ជាការពិតណាស់ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើផែនការសង្គ្រាម ដើម្បីរំដោះពេលប្រទេសជាតិរួច ផុតពីភាពអន្តរាយ ។ យុទ្ធសាស្ត្រប្រយុទ្ធសម្រាប់សត្រូវពិតជាត្រូវបានប្រើប្រាស់ដើម្បីទទួលបានជ័យ ជំនះ ។ ការធ្វើបែបនេះ ខ្ញុំគិតថាវាមិនមែនជាការខុសច្បាប់ទេ" ។ គាត់លើកយកប្រទេសចំនួនប្រាំ ដែលធ្លាប់ជួនទូវសង្គ្រាមស៊ីវិល ថាប្រទេសទាំងនោះសុទ្ធសឹងតែមានផែនការ ដើម្បីកម្ទេសសត្រូវរបស់ ខ្លួនទៅវិញទៅមក ។

គាត់បន្ថែមថា "ប្រសិនបើតុលាការចាត់ទុកថា ការធ្វើផែនការប្រយុទ្ធនៅក្នុងពេលធ្វើសង្គ្រាម ដើម្បីទទួលបានជ័យជម្នះជាចេតនាប្រព្រឹត្តបទល្មើស ដូចលោក លោកស្រីសហព្រះរាជអាជ្ញាចោទ ប្រកាន់មែននោះ ម្ល៉េះសមមេដឹកនាំនៃប្រទេសទាំងអស់នោះ មិនថារដ្ឋាភិបាល ឬក្រុមប្រឆាំងនោះទេ ត្រូវតែយកមកកាត់ទោសដូចគ្នា ជាពិសេសសហរដ្ឋអាមេរិក វៀតណាម រួមទាំងមេដឹកនាំខ្មែរដទៃ ទៀតផង ។ កុំយកតែខ្លួនក្រពើមកកាត់ទោស តែក្បាល និងកន្ទុយទុកនៅដោយខ្សែករួចពីសំណាញ់ ច្បាប់" ។

ចុងក្រោយ នួន ជា បង្វែរសណ្ឋវិញទៅលើផែនការប្រយុទ្ធគ្នា ឬកម្ទេចសត្រូវត្រូវបាន បញ្ចប់នៅពេលបញ្ចប់សង្គ្រាម និងវិសាលភាពនៃការកាត់ទោសចំពោះតែអំពើទាំងឡាយណាដែលកើត ឡើងក្នុងចន្លោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩ ។ គាត់និយាយថា "បើទោះជាខ្ញុំមិនចេះច្បាប់ក៏ដោយ ក៏ខ្ញុំយល់ថាការអះអាងរបស់លោក លោកស្រីសហព្រះរាជអាជ្ញា អំពីសកម្មភាពរបស់ខ្ញុំនៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពិតជាអំណះអំណាងខុសច្បាប់ និងគ្មាន តម្លៃតាមផ្លូវច្បាប់" ។

ពេលវេលាគឺជិតដល់ម៉ោង១០ព្រឹក លោកមេធាវីការពារក្តី របស់ នួន ជា លោក សុន អរុណ បានបង្អាក់ការធ្វើសេចក្តីសន្និដ្ឋានរបស់កូនក្តីខ្លួន ដោយត្រូវនឹងពេលដែលគាត់ត្រូវសម្រាក ។ ប្រធានអង្គជំនុំជម្រះ ណុន ក៏ប្រកាសសម្រាកចាប់តាំងពីពេលនេះតទៅរហូតដល់ម៉ោង១០ៈ១៥នាទី ។

## ការបកស្រាយការសម្រេចចិត្តជម្លៀសចេញពីទីក្រុងភ្នំពេញ

នៅពេលត្រលប់មកកាន់អង្គសវនាការវិញនៅម៉ោង១០ៈ១៥នាទីព្រឹក នួន ជា បន្តធ្វើ សេចក្តីសន្និដ្ឋានបិទបញ្ចប់ ដោយលើកយកការជម្លៀសប្រជាជនជាប្រធានបទ ។ គាត់បដិសេធថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញជាការជម្លៀសដោយបង្ខំ ។ គាត់លើយកនូវហេតុផលលម្អិត

ចំនួនពីរនៃការជម្លៀសនេះ ទីមួយ ការភ័យខ្លាចការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងបញ្ហាប្រឈមកង្វះស្បៀងអាហារនៅពេលប្រទេសមានសង្គ្រាម ។ គាត់រំឭកអ្នកស្តាប់ទាំងអស់គ្នាថា នៅពេលនោះ ប្រទេសកម្ពុជាមិនទាន់មានជំនួយពីបរទេសទេ ។

នួន ជា រៀបរាប់ថា ស្ថិតនៅក្នុងកាលៈទេសៈបន្ទាន់បែបនេះ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានរៀបចំផែនការជម្លៀសប្រជាជនទៅតាមតំបន់ និងខេត្តណាដែលមានធនធានសេដ្ឋកិច្ច ស្រូវអង្ករអាចចិញ្ចឹមប្រជាជនបាន និងទាមទារឲ្យប្រជាជនចូលរួមក្នុងការបង្កបង្កើនផលដោយខ្លួនឯងសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅ និងកសាងប្រទេសជាតិ ។ គាត់បន្តថា គ្រប់លេខាភូមិភាគដែលជាសមាជិកគណៈមជ្ឈិមបក្សបានចូលរួមកិច្ចប្រជុំនេះ ។ ភូមិភាគពាយ័ព្យបានធានាទទួលយកប្រជាជនចំនួន១,៥លាននាក់ ហើយភូមិភាគបូព៌ា ភូមិភាគនិរតី និងភូមិភាគកណ្ដាលបានធានាទទួលយកប្រជាជនដែលនៅសេសសល់ ។ គាត់បន្ថែមទៀតថា ក្នុងផែនការនោះ គឺភូមិភាគនីមួយៗមានស្វ័យភាពក្នុងការជួយសម្រួលគ្នាទៅវិញទៅមកទាក់ទងនឹងការជម្លៀសនេះ ។ «ទោះជាមានហេតុផលទាំងពីនេះក្ដី ការជម្លៀសប្រជាជននៅពេលនោះ ធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំ គ្មានអំពើហិង្សា ឬសម្លាប់ប្រជាជននោះទេ ។ ប្រការនេះត្រូវអនុវត្តតាមរយៈការពន្យល់ប្រជាជន ឲ្យបានយល់ដឹងច្បាស់ពីស្ថានភាពគ្រោះថ្នាក់នៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុង និងតម្រូវការចាំបាច់នៃការដោះស្រាយជីវភាព និងកសាងប្រទេសដោយខ្លួនឯង» ។

នួន ជា បន្តថា នៅពេលនោះប្រជាជនបានយល់ពីស្ថានភាពគ្រោះថ្នាក់ និង«តម្រូវការចាំបាច់» របស់ប្រទេសជាតិ ជាពិសេសប្រជាជន «បានគាំទ្រ និងស្រលាញ់បដិវត្តន៍» ។ ទាក់ទងនឹងចំណុចនេះគាត់សូមបំភ្លឺចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ថាធ្លាប់គិតទេថាទាហាន លន់ នល់ បានបាញ់ផ្លោងដោយកាំភ្លើងធំ (ដែលសហរដ្ឋអាមេរិកផ្ដល់ឲ្យអស់រាប់លានគ្រាប់) ដែលបានបំផ្លិចបំផ្លាញផ្ទះសម្បែង វត្តអារាម ទ្រព្យសម្បត្តិ សាលា ចម្ការ និងសត្វពាហនៈរបស់ប្រជាជន ។ «តើនេះមិនមែនជាអំពើអមនុស្សធម៌ ឬជាឧក្រិដ្ឋកម្មទេឬ? នួន ជា ចោទសួរ ។

បង្វែរទៅកាន់ការចោទប្រកាន់មួយវិញទៀត ចំពោះអ្វីដែលបានលើកឡើងអំពីកម្ពុជាប្រជាធិបតេយ្យជា «រដ្ឋទាសករ» ធ្វើឲ្យ នួន ជា បដិសេធទាំងស្រុងថា «នេះវាជារឿងមួយមិនអាចទទួលយកបានទេ» ។ «ខ្ញុំសូមបញ្ជាក់ជូនបងប្អូនជនរួមជាតិថា បក្សកុម្មុយនីស្តកម្ពុជាមិនមែនតស៊ូ រំដោះប្រទេសកម្ពុជាក្នុងគោលបំណងដាក់ប្រជាជនកម្ពុជាជាទាសករដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ» ។ តាមគំនិតផ្ទាល់របស់គាត់ បក្សកុម្មុយនីស្តកម្ពុជារំដោះប្រជាជនពីទាសភាព ព្រោះបណ្ដាលមកពីការចាក់ឫសយ៉ាងជ្រៅនៃអំពើពុករលួយ និងភាពអយុត្តិធម៌នៅក្នុងសង្គមកម្ពុជា ។ គាត់រៀបរាប់ពី ពួកនាយទុនឆ្កៀតពេលដែលប្រជាជនមានទុក្ខលំបាក ទារបង់ពន្ធ និងការប្រាក់តាមទំនើងចិត្ត នៅពេលដែលពួក

គេខ្ចីបុលពួកនាយទុន ប្រឈមមុខនឹងការប្រាក់ហួសហេតុ ដែលនាំឲ្យប្រជាជនទាំងនោះគ្មានលទ្ធភាពសងបំណុល ហើយត្រូវបានម្ចាស់បំណុលរឹបអូសយកដីស្រែ ចម្ការ និងផ្ទះសម្បែង ដែលពេលនេះប្រជាជនទាំងនោះត្រូវបង្ខំចិត្តស៊ីឈ្នួលគេ ដើម្បីកាត់បំណុល ឬបង្ខំចិត្តឲ្យលក់កូនធ្វើជាខ្ញុំគេ ជីវភាពកាន់តែក្រទៅៗ ។ នួន ជា សង្កត់ធ្ងន់ថា គោលបំណងរបស់គាត់គឺកសាងប្រទេសជាតិ ឲ្យប្រជាជនរស់នៅស្មើភាពគ្នា ក្នុងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយសម្រេចជោគវាសនាជាតិខ្លួនដោយខ្លួនឯង ។

## គម្រោងផែនការបួនឆ្នាំៈ បន្ថែមជារៀងរាល់ថ្ងៃ

នួន ជា បន្តពិណ៌នាលើស្ថានភាពដែលកម្ពុជានឹងប្រែក្លាយជា ក្នុងកំឡុងពេលបួនឆ្នាំខាងមុខ ប្រសិនបើគម្រោងផែនការដែលរៀបចំឡើងដោយគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជានេះ អាចសម្រេចបាន ។ ការកសាងសង្គមនិយមតាមមាគ៌ា និងអនុវត្តតាមផែនការបួនឆ្នាំនេះបាន ប្រជាជនម្នាក់ៗនឹងទទួលបានផ្លែផ្កាដូចតទៅៈ

- ប្រជាជនម្នាក់ៗទទួលអាចទទួលនូវរបបអាហារចំនួន៣១២គីឡូក្រាមស្រូវក្នុងមួយឆ្នាំ និងមានអាហារហូបគ្រប់គ្រាន់បីពេលក្នុងមួយថ្ងៃ ជាមួយនឹងម្ហូបពីរមុខគឺ (សម្លទឹកនិងសម្លគោក)
- រួមទាំងចំណី និងបង្អែម ជារៀងរាល់បីថ្ងៃម្តងក្នុងឆ្នាំ១៩៧៧
- បង្អែមជារៀងរាល់ពីរថ្ងៃម្តងក្នុងឆ្នាំ១៩៧៨
- បង្អែមជារៀងរាល់ថ្ងៃចាប់តាំងពីឆ្នាំ១៩៧៩ នេះតទៅ
- ធ្វើការប្រាំបីម៉ោងក្នុងមួយថ្ងៃ ហើយឲ្យឈប់សម្រាកបីថ្ងៃក្នុងមួយសប្តាហ៍
- ច្បាប់សម្រាប់មាតុភាពមានរយៈពេលពីរខែ និងឈឺត្រូវបានឲ្យឈប់សម្រាកតាមជាក់ស្តែង ។

លើសពីនេះទៀត របបនេះបានរៀបចំបង្កើតគ្រឿងចក្រឲ្យកាន់តែច្រើន សម្រាប់សម្រាលទម្ងន់ការងារដោយកម្លាំងកាយឲ្យផ្ទាល់របស់ប្រជាជន ។ នួន ជា បញ្ជាក់ថា គោលជំហររបស់បក្សកុម្មុយនីស្តកម្ពុជាមិនបានបង្ខំឲ្យប្រជាជនធ្វើការធ្ងន់ធ្ងរនេះឡើយ ។ ហើយគាត់សារភាពថា ក្រោយឆ្នាំ១៩៧៩ ទើបគាត់ដឹងច្បាស់ថា កម្មាភិបាលមូលដ្ឋាននោះបានកុហកខ្ញុំថា ប្រជាជនមានស្មារតីប្តេជ្ញាខ្ពស់ ស្ម័គ្រចិត្ត ធ្វើការបន្ថែមនៅពេលយប់ ។

## នួន ជា ធ្វើសេចក្តីសន្និដ្ឋានមិនបញ្ចប់ ដាក់កំហុសលើអ្នករាល់គ្នា មិនមែនរូបគាត់

នួន ជា បន្ទោសលើយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការជ្រើសរើសកម្មាភិបាលមួយចំនួនខុស មិនបានវែកញែកឲ្យដាច់នូវសត្រូវ ភ្នាក់ងារបង្កប់របស់វៀតណាម និងអាមេរិកដែលក្បត់បដិវត្តន៍ អ្នកដែលមិនធ្វើតាមផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ("បែរជានាំគ្នាកាប់សម្លាប់ និងធ្វើបាបប្រជាជនដោយការបង្អត់អាហារ ការបង្ខំឲ្យធ្វើការហួសកម្លាំងតាមទំនើងចិត្តរបស់ខ្លួន ហើយលាក់បាំង និងរាយការណ៍ភូតកុហកមជ្ឈិមបក្ស ធ្វើយ៉ាងណាឲ្យបដិវត្តន៍ចុះខ្សោយ ហើយសត្រូវយកលេសថាមករំដោះប្រជាជនកម្ពុជាដើម្បីការឈ្លានពានរបស់វៀតណាម") ។

នួន ជា បង្វែរប្រធានបទមករកភាពយុត្តិធម៌នៅក្នុងពេលកាត់សេចក្តី ។ "តាមការសង្កេតរបស់ខ្ញុំនៅក្នុងសវនាការនេះ សិទ្ធិជាមូលដ្ឋានមួយចំនួនរបស់ខ្ញុំត្រូវបានរំលោភបំពាន" សម្តីរបស់ នួន ជា ។ តុលាការមានភាពលម្អៀង មិនបានកោះហៅសាក្សីសំខាន់មកបំភ្លឺនៅចំពោះមុខតុលាការ ភាពមិនស្មើភាពគ្នាក្នុងការប្រមូលរកឯកសារភស្តុតាង ។ គាត់និយាយថា "លោក លោកស្រីចៅក្រមត្រូវតែរំពឹងលើសក្ខីកម្មទាំងនេះ ទោះបីជាមានការរំខានពីអារម្មណ៍ផ្ទាល់ខ្លួន ដើម្បីយុត្តិធម៌" ។ "ដោយមើលឃើញភាពអយុត្តិធម៌បែបនេះ ទាំងរូបខ្ញុំក៏ដូចជាលោក ខៀវ សំផន បានសម្រេចចិត្តឈប់ផ្តល់សក្ខីកម្មជូនតុលាការ ពីព្រោះយើងយល់ថា បើទោះជាយើងផ្តល់ចម្លើយជូនចៅក្រម ក៏វាមិនមានន័យអ្វីដែរ ដោយហេតុថាចៅក្រមមានភាពលម្អៀង ហើយអ្វីដែលអនុវត្តនៅចំពោះមុខតុលាការនោះ វាគ្រាន់តែជាការបន្ត្រប់នីតិវិធី ឬបំពេញទម្រង់ឲ្យល្អមើលតែប៉ុណ្ណោះ" នេះជាអ្វីដែលគាត់បានរៀបរាប់ ។

នួន ជា ធ្វើការសន្និដ្ឋានដោយផ្អែកលើមូលដ្ឋានទាំងបីខាងលើ យោងតាមភស្តុតាងៈ

...បង្ហាញថា ខ្ញុំមិនបានធ្វើផែនការប្រព្រឹត្តបទល្មើស ។ ខ្ញុំមិនបានជួយឧបត្ថម្ភ ឬលើកទឹកចិត្តឲ្យជនណាម្នាក់ប្រព្រឹត្តបទល្មើស ។ បើទោះជាខ្ញុំមានតួនាទីជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា ខ្ញុំមិនបានដឹងអំពីការប្រព្រឹត្តិបទល្មើសនៅតាមមូលដ្ឋាននោះទេ ។ ទើបតែនៅជិតចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ទើបខ្ញុំបានដឹងអំពីអំពើក្បត់របស់មេដឹកនាំនៅតាមតំបន់ភូមិភាគ តំបន់ និងនៅតាមមូលដ្ឋានខ្លះ ដែលមានបំណងបំផ្លាញចលនាបក្សកុម្មុយនីស្តកម្ពុជា ។ ហើយនៅពេលនោះ ខ្ញុំពិតជាគ្មានអំណាចក្នុងការទប់ស្កាត់អំពើក្បត់ទាំងនោះបានឡើយ ពីព្រោះខ្ញុំពុំមានតួនាទីគ្រប់គ្រងផ្ទាល់លើកងកម្លាំងយោធា ឬរដ្ឋអំណាចមូលដ្ឋានទាន់តែសោះ ។

ប្រសិនបើក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំពិតជាមានអំណាចដឹកនាំ ឬបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នៅពេលនេះប្រាកដជាតុលាការដែលបង្កើតដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៧៩ (ស៊ីក) ពិតជាកាត់ទោសខ្ញុំដូច ប៉ុល ពត និង អៀង សារី ទៅហើយ ។ ពីព្រោះពេលនោះ គឺភស្តុតាងនៃឧក្រិដ្ឋកម្មនៅបន្សល់ទុកនៅថ្មីៗនៅឡើយ មិនបាច់រង់ចាំពេល៣៨ឆ្នាំ

ដើម្បីកាត់ទោសខ្ញុំទេ ។ តែដោយសារដឹងថាខ្ញុំគ្មានអំណាចអ្វី និងមិនបានប្រព្រឹត្ត ។ ទោះបីជាយ៉ាងណា ខ្ញុំនៅតែសម្តែងនូវការសោកស្តាយជាទីបំផុត និងសូមទទួលខុសត្រូវផ្នែកសីលធម៌ចំពោះជនរងគ្រោះទាំងអស់ និងប្រជាជនកម្ពុជាទាំងមូលដែលបានទទួលរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាការពិតសម្រាប់ប្រវត្តិសាស្ត្រ ទាំងគោលនយោបាយ ទាំងមាគ៌ា និងទាំងផែនការរបស់ចលនាបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឡើងក្នុងគោលបំណងតែមួយគត់ គឺរំដោះប្រទេសជាតិ និងប្រជាជនឲ្យរួចផុតពីអាណានិគមនិយម ចក្រពត្តិនិយម និងការជិះជាន់កេងប្រវ័ញ្ច ភាពក្រីក្រទីបំផុតគ្មានការជ្រៀតជ្រែក និងការឈ្លានពានពីប្រទេសជិតខាង ពិសេសពីប្រទេសវៀតណាម ។ យើងចង់បានសង្គមមួយដែលមានភាពស្មើគ្នា ។

នួន ជា និយាយបន្ថែមទៀតអំពីសោកនាដកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសូមអភ័យទោសចំពោះជនរងគ្រោះ ក្រុមគ្រួសារជនរងគ្រោះ នងប្រជាជនកម្ពុជាទាំងមូល ថាៈ

ខ្ញុំនៅតែប្រកាន់ជំហរទទួលខុសត្រូវលើផ្នែកសីលធម៌ចំពោះការគ្រប់គ្រងមិនបានដិតដល់ និងមិនបានគ្រប់ជ្រុងជ្រោយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយខ្ញុំសូមគោរពវិញ្ញាណក្ខន្ធដល់ប្រជាជនដែលរងគ្រោះដោយគ្រប់យថាហេតុទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំឃើញច្បាស់ថាយុត្តិធម៌អាចប្រែប្រួលទៅតាមកាលៈទេសៈ តែសច្ចធម៌ជាអមតធម៌មិនប្រែប្រួលជាដាច់ខាត ។ ពពកខ្មៅមិនអាចបិទបាំងពន្លឺព្រះអាទិត្យបានទេ ។ យ៉ាងណាមិញមនុស្សអគតិ អសីលធ៌ម មិនអាចភូតកុហក និងបិទបាំងភ្នែកប្រជាជន និងមហាជនមិនឲ្យមើលឃើញនូវសច្ចធម៌នៃការតស៊ូដ៏អង់អាចក្លាហានរបស់ប្រជាជនកម្ពុជា និងការខបត្តម្ភគាំទ្ររបសប្រជាជនស្នេហាសន្តិភាព និងយុត្តិធម៌លើសកលលោកបានឡើយ ។

អាស្រ័យហេតុនេះ ដោយផ្អែកលើភស្តុតាង និងហេតុផលទាំងអស់ខាងលើនេះ និងជាពិសេសសេចក្តីសន្និដ្ឋានរបស់មេធាវីខ្ញុំ ខ្ញុំសំណូមពរតុលាការមេត្តាសម្រេចឲ្យខ្ញុំបានរួចផុតពីបទចោទប្រកាន់ក្នុងសំណុំរឿងនេះ និងសូមដោះលែងខ្ញុំឲ្យមានសេរីភាពវិញទៅតាមផ្លូវច្បាប់ ។ សូមអរគុណ ។ សូមអស់សូមអរគុណលោកប្រធាន ។

## ក្ល. បន្តដំណើរការនីតិវិធីធ្វើសេចក្តីសន្និដ្ឋានតបស្នាពរចុងក្រោយមុនបិទបញ្ចប់

នួន ជា បានធ្វើការបិទបញ្ចប់ នៅវេលាម៉ោង១០ៈ៥០ព្រឹក ដោយចំណាយពេលពីរម៉ោងលើការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ហើយក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន មានបំណងចង់ប្រើប្រាស់ពេលវេលាខ្លះដែលនៅសល់ តែមេធាវីការពារក្តីរបស់ នួន ជា កូបេបានប្រើពេលវេលាប្រមាណ៤៥នាទី ក្នុងការធ្វើសេចក្តីសន្និដ្ឋានតបស្នាពរចុងក្រោយ ។

ដូចអ្វីដែលមេធាវីការពារក្តីបានធ្វើរាល់ដងនៅពេលបិទបពាប់សេចក្តីសន្និដ្ឋានរបស់ខ្លួន កូប៉េបាន លើកយកទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឆ្លើយតប ដោយចាប់ផ្តើមទៅនឹងការត្រាប់តាមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឃ្លារបស់សហព្រះរាជអាជ្ញាដែលហៅថា «រដ្ឋទាសករ» ។ គាត់និយាយថា ឃ្លានេះដូចជា «ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញាបានបំភ្លឺមកបញ្ចាំងមុខយើងដូចជាភ្លើងណេអុងដូច្នោះដែរ ។ ហើយការប៉ុនប៉ងរបស់គាត់ គឺចង់អះអាងថាការធ្វើបែបនេះឆ្លុះបញ្ចាំងពីគោលបំណងរួមរបស់បក្សកុម្មុយនីស្តកម្ពុជា» ។ ប៉ុន្តែគាត់បដិសេធថា ការប្រើពាក្យនៅឃ្លានេះជាពាក្យស្លោកថា «រដ្ឋទាសករ» នោះមិនត្រឹមត្រូវទេ ហើយធ្វើឲ្យមានការភ័ន្តច្រឡំនោះដែរ ។ កូប៉េ លើកឡើងថា គឺមិនត្រឹមតែមិនបានផ្អែកទៅលើភស្តុតាងដែលស្ថិតនៅក្នុងបញ្ហាត្រូវពិភាក្សានៅចំពោះតុលាការទេ ប៉ុន្តែមូលដ្ឋាននៅក្នុងចម្លើយសាក្សី និងភស្តុតាងទាំងអស់នោះគឺស្ថិតនៅក្រៅវិសាលភាពនៃរឿងក្តី០០២/០១ ។ គាត់បន្ថែមថាចមេ់យសារភាពរបស់សាក្សីត្រូវបានព្យាយាមដាក់បញ្ចូលតាម «ទ្វារក្រោយ» ដែលរំពុកពីលក្ខខណ្ឌសហករណ៍ ដើម្បីបង្ហាញពីបុគ្គលមួយចំនួនដែលត្រូវបានគេចាត់ទុកដូចជាទាសករ ប៉ុន្តែចម្លើយទាំងអស់ដែរត្រូវបានលើកឡើងនោះគឺ ជាការអះអាងក្រៅវិសាលភាពនៃរឿងក្តី០០២/០១ ។

ខណៈពេលនេះ នួន ជា ស្នើសុំការអនុញ្ញាតចេញពីបន្ទប់សវនាការទៅកាន់បន្ទប់ទៅកាន់បន្ទប់ឃុំខ្លួន ហើយអង្គជំនុំជម្រះបានជូនដំណើរគាត់ ។

កូប៉េ ធ្វើការបញ្ជាក់ម្តងទៀតថា អ្វីដែលគេលើកឡើងនេះ គឺថាជាការអះអាងដើម្បីធ្វើឲ្យទ្រឹស្តីរបស់ខ្លួន ឲ្យតុលាការជឿថាជាការពិត តែផ្អែកលើភស្តុតាង ចំណុចនេះមិនជាផ្នែកនៃសវនាការទេ ហើយគ្មានពាក់ព័ន្ធខ្លឹមសារដែលត្រូវលើកមកទេ ។ ជាឧទាហរណ៍ គាត់បានសួរថា មានការសម្លាប់មនុស្ស២លាននាក់ ផ្អែកទៅលើភស្តុតាងដែលមិនបានដេញដោលគ្នា ជាការត្រឹមត្រូវដែរឬទេ? នេះគ្រាន់តែជាឧទាហរណ៍មួយដែលបង្ហាញពីបទចោទមិនមែនជាផ្នែកនៃការជំនុំជម្រះនោះទេ ។ កូប៉េ បន្តទៀតថា ដូចគ្នាយ៉ាងដូចេះដែរ ការអះអាងដែលមិនស្ថិតនៅក្នុងវិសាលភាពក្នុងការដេញដោលនៅក្នុងតុលាការគឺមិនត្រូវបានគេយកមកជំនុំជម្រះទេ ។ ការចោទប្រកាន់ផ្សេងៗ ដូចជាកម្មាភិបាលខ្មែរក្រហមបានសម្លាប់ទារក ហេ់យនិងអ្នកណាដែលពាក់វ៉ែនតា មិនត្រូវបានអនុញ្ញាតនោះទេ ។ «ការចោទបែបនេះគឺថាមិនអាចផ្អែកទៅលើការសន្និដ្ឋានថាមានអំពើនេះកើតនៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ ។ ការអះអាងបែបនេះ គឺគ្មានភស្តុតាងណាបញ្ជាក់ មិនមានអ្នកណាបញ្ជាក់ សាក្សីណាបញ្ជាក់ទេ ។ ការប្រើពាក្យខុសអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងន័យនេះ អង្គជំនុំជម្រះគួរតែច្រានចោលការអះអាងនេះ» នេះជាពាក្យសម្តីរបស់ កូប៉េ ។

បន្ទាប់មក កូប៉េ ធ្វើការឆ្លុះបញ្ចាំងអំពីការចោទប្រកាន់ដោយដើមបណ្ដឹងរដ្ឋប្បវេណី ដែលថាគាត់ការពារកូនក្ដីរបស់គាត់នេះ គាត់បានធ្វើការចំអកឡកឡាយទៅដើមបណ្ដឹងរដ្ឋប្បវេណី ។ ចំណុះនេះគឺគ្មានការអះអាងនោះទេ ។ គាត់ថ្លែងបន្តទៀត យើងមេធាវីការពារក្ដីគឺមិនដែលបដិសេធការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ តាមពិតយើងបានផ្ដល់សន្ដានចិត្តដ៏ខ្លាំងទៅដល់ការឈឺចាប់របស់គេ ។ គួរនិយាយថា គេយល់ខុសអំពីតួនាទីរបស់មេធាវីការពារក្ដី និងរបស់ពួកគេ ។ កូប៉េបញ្ជាក់ថា “ពួកគាត់បានយោងទៅលើសារណារបស់ខ្ញុំក្នុងការប៉ុនប៉ងបង្ហាញថា ការអះអាងរបស់យើងគឺការអះអាងរបស់យើងគឺនៅក្រៅវិសាលភាពនៃការពិតរបស់កម្ពុជាប្រជាធិបតេយ្យ ដោយចុចថា យើងប្រើភាសា “ការជម្លៀស” និង “ការរំដោះ” ប្រជាជន យោងទៅលើរឿងប្រលោមលោករបស់ អូវែលលៀន (Orwellian) ថាជាភាសាថ្មីនោះ” ។ “ក្នុងករណីនេះយើងរំឮកដល់ភាគីទាំងអស់ថា យើងប្រើពាក្យនេះជាបន្តបន្ទាប់ដោយភាគីទាំងអស់នៅក្នុងតុលាការនេះក្នុងការជំនុំជម្រះ ។ ពាក្យទាំងអស់នេះ ដកស្រង់ពីដីការដំណោះស្រាយដោយខ្លួនឯង ។ យើងបានបន្សល់ទុកនូវសារណារបស់យើងដែលមានការប្រើប្រាស់ភាសាយ៉ាងត្រឹមត្រូវ” នេះគឺសម្ដីរបស់ កូប៉េ ។

កូប៉េ បង្វែរចម្លើយតបទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញានិយាយអំពីភាពយុត្តិធម៌នៃការជំនុំជម្រះនេះ ។ សហព្រះរាជអាជ្ញា បញ្ជាក់ថា ក្នុងរយៈពេលពីរថ្ងៃនេះមេធាវីការពារក្ដីពិតជាបានលើកឡើងនៅក្នុងទន្លឹករណ៍ផ្ទាល់មាត់ គឺអង្គជំនុំជម្រះបង្ហាញពីការប្ដេជ្ញាដើម្បីផ្ដល់ការជំនុំជម្រះយុត្តិធម៌ និងថាការបំពានទៅលើការជំនុំជម្រះដោយយុត្តិធម៌នោះ គឺត្រូវដោះស្រាយរួចហើយ ។ “តើនេះមកពីស្ដង់ដាមានកម្រិតទាបឬ?”គាត់សួរទៅកាន់អង្គជំនុំជម្រះ ហើយគាត់ពោលថា “ចម្លើយទៅនឹងបញ្ហាដែលខ្ញុំសួរនេះ គឺថាពិតជាអ៊ីចឹងមែន” ។

## ការខូចខាតការជំនុំជម្រះដោយយុត្តិធម៌

កូប៉េ មានសេចក្ដីក្រេវក្រោធចំពោះតុលាការ ដែលមិនគាំទ្រគាត់ ក្នុងការកោះហៅសាក្សី ហេង សំរិន ដែលជាសាក្សីស្នូល នៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ គាត់មិនត្រឹមតែជាសាក្សីស្នូលទេ តែជាថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់ក្នុងពេលបច្ចុប្បន្នផងដែរ ។ កូប៉េ រៀបរាប់ថា មិនមាននរណាម្នាក់ឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្ដី ថាតើហេតុអ្វីបានជាយើងមិនអាចកោះហៅ ហេង សំរិន ឲ្យមកធ្វើជាសាក្សីបាន ។ កូប៉េ លើកយកនូវហេតុផលជាច្រើនដែលអាចទៅរួច បន្ទាប់ចុងក្រោយបែរជានិយាយថា “លោក លោកស្រីចៅក្រម លោក ហេង សំរិន គឺជា ដូចជាដំរីនៅក្នុងបន្ទប់មួយអ៊ីចឹង គឺថាយើងឃើញច្បាស់ទាំងអស់ទាំងសហព្រះរាជអាជ្ញា និងដើម្បីរដ្ឋប្បវេណីមិនហ៊ានលើកយកមកនិយាយ ។ ហេតុអ្វីបានជាគេមិននិយាយអ្វីទាល់តែសោះអំពីគាត់បែបនេះ? យើងអាចឃើញមាន

មូលហេតុពីរ គេអាចយល់ស្របថាវគ្គមានរបស់គាត់គឺ មានសារៈសំខាន់ណាស់ដើម្បីការជំនុំជម្រះដោយយុត្តិធម៌ មិនអាចទប់ទល់បាននឹងសក្ខីកម្មរបស់គាត់ ឬមួយក៏យើងមិនចាំបាច់សូម្បីតែបញ្ជាក់ឈ្មោះគាត់ក៏មិនចាំបាច់ដែរ ។ នេះជាអ្វីដែល កូប៉េ បញ្ជាក់ដល់សហព្រះរាជអាជ្ញា ហាក់បីដូចជាស្ថិតក្នុងឆន្ទះរបស់រដ្ឋាភិបាលដែលធ្វើឲ្យបញ្ហានេះកាន់តែមានការអាក្រក់ ហើយថាកូនក្តីខ្លួននឹងមានការ «រំលោភបំពានសិទ្ធិ» ។

កូប៉េ បន្តថា «ការជំនុំជម្រះនេះមានលក្ខណៈជានយោបាយមូលដ្ឋាន ។ ដំណើរការនីតិវិធីបែបនេះមិនអាចបំបែកចេញឲ្យដាច់ច្បាប់ និងនយោបាយនោះទេ ។ សាលាក្តីបែបនេះគឺអាចនឹងប្រើច្បាប់លាយជាមួយនឹងនយោបាយ ។ នេះជាទស្សនៈដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រនៃដំណើរការព្រហ្មទណ្ឌអន្តរជាតិជាយូរមកហើយ ។ តើអ្នកដែលឈ្នះនៅក្នុងសង្គ្រាម គប្បីតែកាត់ទោសដូចជាអ្នកចាញ់ដែរ អាចមានឬទេ?» លើសពីនេះទៀត «នួន ជា មានទស្សនៈថា គាត់មិនអាចបានជំនុំជម្រះដោយយុត្តិធម៌ ដោយតំណាងភាគីដែលឈ្នះទាំងអស់ទេ» ។

សហព្រះរាជអាជ្ញា បានដាក់បញ្ចូល៤០ទំព័រជាការវិភាគប្រវត្តិសាស្ត្រក្នុងសារណារបស់ខ្លួនតែត្រូវ កូប៉េសួរថាប្រវត្តិសាស្ត្រជាអ្វី? ហេតុអ្វីបានជាអះអាងថា អំពើហិង្សារបស់បក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥ មិនមានរៀបរាប់ពីការទម្លាក់គ្រាប់បែកអាមេរិកកាំង? តើមានចម្លល់ទេអំពីចេតនារបស់បក្សកុម្មុនស់កម្ពុជា ទាក់ទងទៅនឹងអំពើឃោឃៅរបស់ខ្មាំង របស់គេក្នុងចម្បាំងនោះដែរឬទេ? តើសហព្រះរាអាជ្ញាអាចហ៊ានចោទប្រកាន់អ្នកទាំងឡាយនៅក្នុងប្រទេសទាំងនេះដែលជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយរបស់កូនក្តីខ្ញុំ? លោកប្រធាន លោក លោកស្រីចៅក្រម គឺថាចម្លើយគឺគេនឹងឆ្លើយថា «ទេ» ។

កូប៉េ បន្តលើកយកករណី នួន ជា លើការសម្រេចចិត្តបដិសេធមិនដាក់ខ្លួនគាត់ឲ្យតុលាការសួរដេញដោលទេ ។ ហើយការមិនបន្តធ្វើដូច្នេះដោយសារថាមានការបំពានសិទ្ធិរបស់គាត់នៅក្នុងការជម្លៀស នៅក្នុងការប្រើភស្តុតាង នៅពេលវេណលោក ហេងឌ័រ ។

កូប៉េ សូមរំឭកឡើងវិញអំពីការភ័ន្តច្រលំពីសហព្រះរាជអាជ្ញា ដែលបានបកស្រាយខុសនូវការលើកឡើងរបស់យើង ដែលថា ការជម្លៀសលើកទី២ ត្រូវបានធ្វើឡើងដោយមេដឹកនាំ «ភូមិភាគក្រហម» តែតាមពិតយើងមិនដែលនិយាយបែបនេះទេ នេះគឺជាការបកស្រាយរបស់ពួកគេ ហើយវាមិនមានន័យអ្វីទាល់តែសោះ ។ មេដឹកនាំតំបន់ភូមិភាគទេ ជាអ្នកគ្រប់គ្រង ហើយមានសិទ្ធិអំណាចទៅលើការជម្លៀសនេះ មិនមែនមេដឹកនាំភូមិភាគក្រហមទេ» ។

## ប្រាំមួយចំណុចសំខាន់ៗលើការពិភាក្សាអំពីទួលពោធិ៍ជ្រៃ

កូប៉េ បានលើកយកចំណុចចុងក្រោយអំពីទួលពោធិ៍ជ្រៃមកនិយាយ ជាដំណាក់ការតាមពេលវេលាកំណត់ដែលនៅសល់ ។ ចំណុចគោលសំខាន់ៗ មានដូចខាងក្រោមៈ

- សហព្រះរាជអាជ្ញា មិនបានជំទាស់ និងមិនបានប្រឆាំងអ្វីទាំងអស់ លើការមិនលើកឡើងទាក់ទងនឹងភស្តុតាងផ្ទាល់ដែលថាមាន គោលនយោបាយក្នុងការសម្លាប់ទាហាន និងមន្ត្រីរដ្ឋការលន់នល់ ហើយគេក៏មិនបានប្រាប់អង្គជំនុំជម្រះថាវាមិនអាចទុកចិត្តបានទេ
- យោងទៅតាមការលើកឡើងរបស់ កូប៉េ រូបថតពីសន្ទឹកជាភស្តុតាងដែលបានបង្ហាញ គឺមិនអាចយកជាការបានទេ
- សារណារបស់យើង គឺថាសហព្រះរាជអាជ្ញាមិនបានបង្ហាញឲ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់អំពីអត្ថិភាពនៃគោលនយោបាយដែលដឹកនាំដោយមជ្ឈិមនោះឡើយ
- ការបដិសេធរបស់ កូប៉េ លើការអះអាងរបស់សហព្រះរាជអាជ្ញាដែលថាយើងមិនអាចឆ្លើយតបសូម្បីតែការអះអាងសំខាន់របស់ពួកគេទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ ។ ភាពស្រពេចស្រពិលនៅក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញាទៅលើការប្រព្រឹត្តរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះខ្មាំង ដូច្នេះហើយគឺថាមិនមានភស្តុតាងណាមួយដែលថា មនុស្សបែបនេះ ឬថាក្រុមមនុស្សបែបនេះ ត្រូវបានគេសម្លាប់ជាប្រព័ន្ធនោះឡើយ ។
- ទ្រឹស្តីវណ្ណៈដែល ឌុច បានអះអាងថាមាននៅក្នុងទស្សនាវដ្តីទង់បដិវត្តហ្នឹង គឺមិនមែនមានន័យថាជាការសម្លាប់នោះទេ ។ “ហេតុផលតែមួយគត់នេះ ក៏គ្រប់គ្រាន់ដើម្បីឲ្យអង្គជំនុំជម្រះបានចោទទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ” សម្តីរបស់ កូប៉េ ។
- ការបញ្ចប់នូវការប្រយុទ្ធសង្គ្រាមស៊ីវិល បង្ហូរឈាមរយៈពេលមួយឆ្នាំ ។ ការសម្លាប់ដោយសងសឹកប្រហែលជាអាចកើតមាន ។

ការសន្និដ្ឋានចុងក្រោយរបស់ កូប៉េ សំដៅលើការវិភាគរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹង រស់ ញឹម នៅក្នុងតួនាទីបក្សកុម្មុយនីស្តកម្ពុជា និងនៅក្នុងតួនាទីនៃអ្នកដឹកនាំមជ្ឈិមនៃអ្នកដឹកនាំទាំងមូល ។ “ចំណុចសំខាន់ គឺថាខ្ញុំមិនអាចនិយាយឲ្យច្បាស់លើសពីនេះទេថា រស់ ញឹម មិន មែនគ្រាន់តែមេដឹកនាំភូមិភាគនោះទេ ។ គាត់គឺជាសមាជិកគណៈអចិន្ត្រៃយ៍ បើផ្អែកទៅតាម ការលើកឡើងរបស់ព្រះរាជអាជ្ញា គឺបានចូលរួមដូចគ្នានៅក្នុងការអនុវត្តរបស់គណៈមជ្ឈិម ទាក់ទងទៅនឹងការអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំ ។ នួន ជា ជួប រស់ ញឹម ជារៀងរាល់ បីខែម្តង នៅក្នុងភូមិភាគពាយព្យ ។ ដូច្នេះសំណួរខ្ញុំគឺថា ថាតើម៉េចដែរ ប្រសិនបើការពិតថា រស់ ញឹម ជួប នួន ជា? តើពួកគាត់អាចនិយាយអ្វីអំពីទំនាក់ទំនងនោះបាន គ្រាន់តែជួបគ្នាប៉ុណ្ណឹង? ពាក្យសម្តីរបស់ អៀង សារី គឺថា“ភូមិភាគនីមួយៗគឺឯករាជ្យ (សម្លាប់អ្វីតាមដែលចង់ ធ្វើខ្លួនតាមដែលខ្លួនចង់)” ។ ការពិតនោះគឺថា ចុង

គេក្រោយគាត់ត្រូវគេសម្លាប់ ត្រូវគេបោសសម្អាតផងដែរ ។ ប្រសិនបើ នួន ជា អាចគ្រប់គ្រង រស់ ញឹម ដោយងាយស្រួលនោះ ហេតុអ្វីពួកគេគិតថាវាចាំបាច់ត្រូវប្រើប្រាស់កម្លាំងទាហានប្រឆាំងជាមួយ រស់ ញឹម នោះ?

## វ៉ែកគែន សហមេធាវីការពារក្តី លោក ខៀវ សំផន ធ្វើសេចក្តីសន្និដ្ឋាន

បន្ទាប់ពីសវនាការសម្រាកសម្រាប់វេលាអាហារថ្ងៃ នៅរសៀលម៉ោង១៍ៈ៣០នាទី អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ដោយផ្តល់វេទិកាជូនដល់សហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលតបចុងក្រោយ ។ ការលើកឡើងរបស់គាត់គឺមានលក្ខណៈខ្លី ហើយសង្ខេប ដូចតទៅ «យើងមិនបានព្យាអ្វីដែលធ្វើយុត្តកម្មមកលើចម្លើយរបស់យើងកាលពីម្សិលមិញទេ ។ ជួនដោយហេតុថា អំណះអំណាងដែលខាងម្ខាងទៀតបានលើកឡើងនោះមិនមានភាពពាក់ព័ន្ធ ។ ជួនគឺថាដោយសារយើងបានឆ្លើយតបទៅនឹងបញ្ហានេះអស់ហើយ នៅក្នុងសារណាបញ្ចប់របស់យើង ហើយនិងតាមការនិយាយនៅក្នុងសវនាការនេះផ្ទាល់តែម្តង» ។

គាត់លើកយកអំណះអំណាងមួយ ដោយយល់ថា វាពុំមានភាពពាក់ព័ន្ធនោះ គាត់មិនបន្តនិយាយឲ្យលម្អិតជាងនេះទៀតទេ ។ គាត់លើកយកអំណះអំណាងមួយទៀតដែលស្ថិតនៅក្នុងវិសាលភាពរឿងក្តី «អំណះអំណាងរបស់យើងវាមិនមានប្រយោជន៍អីទេ មិនបាច់វែងឆ្ងាយទៀតទេ យើងបានឆ្លើយតបហើយ ផ្តល់អំណះអំណាងអស់ហើយ» ។

មានការលើកយកពីបញ្ហាបរិបទប្រវត្តិសាស្ត្រលើស្ថានភាពផ្សេងៗយកមកបកស្រាយ តែការបកស្រាយ តែការបកស្រាយត្រូវបានបញ្ចប់យ៉ាងឆាប់រហ័ស ។

ទាក់ទងនឹងការជម្លៀសប្រជាជនលើកទីពីរ វ៉ែកគែន បាននិយាយម្តងហើយម្តងទៀតថា ការពិតនៅពេលនោះ គឺថា ខៀវ សំផន ស្ថិតនៅក្រៅប្រទេស ហើយមិនមានភស្តុតាងណាមួយបញ្ជាក់ថា ខៀវ សំផន បានចូលរួមក្នុងការអនុវត្តចលនានេះទេ (កំឡុងខែសីហា ឆ្នាំ១៩៧៥-១៩៧៦) ។

វ៉ែកគែន បញ្ចប់ការសន្និដ្ឋានឆ្លើយតបចុងក្រោយ ដោយលើកយកចំណុចមួយទៀតទាក់ទងទៅនឹង ទម្រង់ទំនួលខុសត្រូវ គឺសហឧក្រិដ្ឋកម្មរួម ។ គាត់រំឭកនូវពេលដែលសហព្រះរាជអាជ្ញាសូមឲ្យតុលាការអនុវត្តលក្ខណៈវិនិច្ឆ័យនៃទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម ។ ក្រៅពីហេតុផលទាំងអស់នេះដែលទាក់ទងនឹងវិសាលភាពនៃសំណុំរឿងយើងនេះ វ៉ែកគែន រំឭកថា បើសិនជាយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្កើតប្រភេទនៃទម្រង់ជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមនេះដែលក្នុង

ទម្រង់នេះ (គឺកម្រិតនៃភស្តុតាងចាំបាច់ ដើម្បីបង្ហាញចេតនាទាបជាងហ្នឹងនោះ) គឺថាមានមូលហេតុច្បាស់លាស់ គឺថាមានបរិបទជាក់លាក់ មិនមែនបង្កើតហ្នឹងមកដើម្បីធ្វើជាកាដូ ផ្ដល់កាដូឲ្យពិភពលោកទេ ហើយនឹងឲ្យខាងសហព្រះរាជអាជ្ញានេះ ។ មូលហេតុហ្នឹងគឺថាពិរុទ្ធជននៃសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ជាប្រព័ន្ធបង្កើតឲ្យចូលរួមក្នុងការបង្កើតជំរំប្រហារជីវិត ។ វ៉ែកកែនបន្តថា “អ្វីដែលសហព្រះរាជអាជ្ញាសូមឲ្យអស់លោក លោកស្រីចៅក្រមធ្វើនៅពេលថ្ងៃនេះ គឺថាឲ្យអស់លោក លោកស្រីចៅក្រមយល់ឃើញថា ប្រទេសកម្ពុជាជាជំរំប្រមូលផ្ដុំមនុស្ស ។ ហើយសូមឲ្យអនុវត្តទម្រង់សហឧក្រិដ្ឋកម្មរួមនេះ ។ នេះមិនត្រឹមត្រូវទាល់តែសោះ ព្រោះថានៅក្នុងបរិបទដែលខ្ញុំបានលើកឡើងនេះហើយ ដែលថាយុត្តិសាស្ត្រនៃឧស្សាហកម្មឧក្រិដ្ឋកម្មរួមនេះត្រូវបានបង្កើតឡើង ។ អីចឹងវាមិនត្រឹមត្រូវនឹងស្មារតីច្បាប់ទេចំពោះការយល់ឃើញដូច្នេះនោះ» ។

ចុងក្រោយ វ៉ែកកែន លើកយកចំណុចដែលក្រុមសហព្រះរាជអាជ្ញានិយាយហួសហេតុ តាមពិតទៅគាត់សុំឲ្យអស់លោក លោកស្រីចៅក្រមអនុវត្តទម្រង់ពន្លាតនៃសហឧក្រិដ្ឋកម្មរួម ។ វ៉ែកកែនរំឭកពីទម្រង់មួយដែល គឺថាតាំងពីមុនការកាត់សេចក្ដីនេះម៉្លេះ ដែលត្រូវបានបដិសេធចេញ ។ សហព្រះរាជអាជ្ញាចង់បង្ហាញអំពីអំណះ ដែលថាទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទត្រូវតែរក្សាតម្កល់ដោយសារថាពួកគាត់នោះដឹងថានឹងអាចមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ ការយល់ឃើញបែបនេះមិនអាចអនុវត្តបានទេនៅចំពោះមុខតុលាការយើងនេះ ព្រោះថាតុលាការនេះបានសម្រេចរួចហើយមុននឹងការបើកជំនុំជម្រះនេះ ហើយថា “សហព្រះរាជអាជ្ញាហ្នឹងក៏បានទទួលដំណឹងនេះដែរ” ។

## ខៀវ សំផន ធ្វើសេចក្ដីសន្និដ្ឋានបទបញ្ចប់កិច្ចពិភាក្សាគបចុងក្រោយ

លោក វ៉ែកកែន ធ្វើការសរុបសេចក្ដីសន្និដ្ឋាននៅរសៀលវេលាម៉ោង ១:៤៥នាទី ហើយប្រគល់វេទិកានេះដល់កូនក្ដីរបស់លោក គឺ ខៀវ សំផនៈ

ក្នុងរយៈប៉ុន្មានថ្ងៃកន្លងមកនេះ ខ្ញុំបានស្ដាប់ច្បាស់អំពីអន្តរាគមន៍របស់ភាគីនានា ។ ហើយជាពិសេសអន្តរាគមន៍របស់អ្នកដែលបន្ទោសខ្ញុំ ថាខ្ញុំបាននិយាយតិចតួចពេកក្នុងរឿងក្ដីរបស់ខ្ញុំនេះ ។ ក៏ប៉ុន្តែព្រមជាមួយគ្នាដដែលនេះ អ្នកដដែលនេះបានប្រើប្រាស់អ្វីដែលខ្ញុំបាននិយាយបន្តិចបន្តួចនោះមកចោទលើរូបខ្ញុំទៅវិញ ។ ហេតុនេះបើទោះជាខ្ញុំនិយាយពន្យល់ ដោយបដិសេធមិនព្រមទទួលការចោទប្រកាន់របស់អស់លោក ក៏អស់លោកនៅតែបន្ទោសខ្ញុំ ។ តែបើខ្ញុំនៅស្ងៀមក៏អស់លោកនៅតែចោទប្រកាន់ខ្ញុំដដែល ។

ខ្ញុំមិនដែលប្រាថ្នា ឬក៏បានសម្រេចជម្លៀសប្រជាជនអ្វីទាល់តែសោះ ។ ហើយខ្ញុំក៏មិនដែលប្រាថ្នា ឬសម្រេចឲ្យមានការកាប់សម្លាប់អ្វីទាល់តែសោះ ។ ជំនឿខាងនយោបាយរបស់ខ្ញុំ អ្វីដែលខ្ញុំ

បានខិតខំធ្វើ សកម្មភាពហូរហែកន្លងមកនេះ គឺដើម្បីការពារអ្នកទន់ខ្សោយ គឺដើម្បីឲ្យគេគោរពនូវសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ហើយដើម្បីប្រទេសជាតិយើង កម្ពុជាយើងមានភាពរឹងមាំ និងឯករាជ្យបរិបូរ ។ ពិតណាស់ ភាពអយុត្តិធមក្នុងសង្គមធ្វើឲ្យខ្ញុំមិនពេញចិត្តទាល់តែសោះ ។ តែវាមិនដល់ថ្នាក់ថាខ្ញុំចង់ឲ្យអ្នកដទៃទទួលភាពអយុត្តិធម៌វិញនោះឡើយ ។ ឧត្តមគតិរបស់ខ្ញុំគឺ ជាតិ ឯករាជ្យភាព និងប្រជាជនរស់នៅបានធូរធារ និងសម្បូរសប្បាយ និងទទួលបាននូវកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន ដូចគេឯងឡើងវិញ ។

ក៏ប៉ុន្តែពេលដែលខ្ញុំបានឮអ្វីដែលចោទប្រកាន់ដល់រូបខ្ញុំ និងរបៀបនៃការចោទប្រកាន់នៅទីនេះ ហើយពេលដែលខ្ញុំមើលឃើញថា អ្នកដែលនឹងត្រូវចូលរួមសម្រេចលើរឿងក្តីរបស់ខ្ញុំនេះបានបដិសេធមិនព្រមពិចារណាដល់សភាពការណ៍ជាក់ស្តែងនូវសម័យកាលនោះ ដោយមើលមកខ្ញុំថាខ្ញុំជាព្រាយបិសាចនោះ ខ្ញុំលែងចង់និយាយស្តីអីទៀតហើយ ។

កាលពីសម័យរដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ ខ្ញុំប្រាថ្នាចង់បានឲ្យខ្មែរក្រហម និងសម្តេច សីហនុ ទទួលបានជ័យជម្នះក្នុងសង្គ្រាម ហើយខ្ញុំបានចូលរួមជាមួយពួកគេ ។ ក្រោយពីការលាលែងរបស់សម្តេច សីហនុ ពីប្រមុខរដ្ឋនៅឆ្នាំ១៩៧៦ ខ្ញុំបានជឿថា មានការកសាងប្រទេសឲ្យបានរីកចម្រើន ។ អស់លោកទាំងអស់គ្នាដែលនៅទីនេះ អស់លោកហាក់ដូចជាជឿជាក់ថា ខ្ញុំខុស ព្រោះអស់លោកទាំងអស់គ្នា ជឿថា ខ្ញុំគួរតែប៉ាន់ប្រមាណមើលឃើញអំពីអ្វីដែលនឹងកើតឡើងនៅក្រោយថ្ងៃ១៧ មេសា ១៩៧៥ ហើយខ្ញុំគួរតែឈប់ចូលរួម ឬក៏រត់គេចខ្លួនចេញពីរបបកម្ពុជាប្រជាធិបតេយ្យ ។

ដោយសារខ្ញុំនៅបន្តតទៅទៀត លោកក៏ចោទថា ខ្ញុំជាពិរុទ្ធជន ។ បើទោះជាខ្ញុំអាចនិយាយបកស្រាយ និងព្យាយាមពន្យល់យ៉ាងណាក៏ដោយ ។ តាមអស់លោក ខ្ញុំគួរតែទុកឲ្យ លន់ នល់ បន្តសកម្មភាពរបស់គេ ។ ខ្ញុំមិនគប្បីតបតនឹងសកម្មភាពរបស់ លន់ នល់ ឡើយ ឬក៏នៅពេលទទួលបានជ័យជម្នះលើសង្គ្រាម លន់ នល់ និងពួកអាមេរិកហើយ ខ្ញុំត្រូវតែដឹងជាមុនថា នយោបាយ និងឧត្តមគតិរបស់ខ្ញុំនឹងមិនត្រូវបានអនុវត្តនោះទេ ។ តែវានឹងត្រូវបង្វែរទៅតាមទិសផ្ទុយពីនេះទៅវិញ ដោយខ្មែរក្រហមដែលគេមានអំណាចគេបានអនុវត្តវិធានការតឹងរ៉ឹងនោះ ។

ខ្ញុំមិនបានឃើញរឿងរ៉ាវដែលអាចកើតឡើងនៅថ្ងៃក្រោយនោះទេ ហើយខ្ញុំក៏មិនមានអំណាចអ្វីទៅដាក់កំហិតឲ្យគេកែប្រែនោះដែរ ។ អ្នកខ្លះថាខ្ញុំជាជនកំសាក ឯខ្ញុំ ខ្ញុំមិនមែនជាអ្នកមានអំណាចអ្វីហើយខ្ញុំក៏មិនខ្វល់អ្វីពីរឿងអត់អំណាចនេះដែរ ។ នេះប្រហែលជាទោសកំហុសរបស់ខ្ញុំ ព្រោះថាក្នុងពេលតៗមក ខ្ញុំក៏ស្ថិតនៅក្បែរអ្នកមានអំណាចផងដែរ តែខ្ញុំគ្មានអំណាចដូចគេទេ ។ តែអស់លោកជឿថាខ្ញុំមានអំណាច ។ ដូច្នេះហើយបានជាថ្ងៃនេះ ខ្ញុំត្រូវបានគេចាប់ខ្លួនយកមកកន្លែងនេះ ។

នៅថ្ងៃនេះ វាងាយស្រួលណាស់ដែលនិយាយថា ខ្ញុំគួរតែដឹងរឿងរ៉ាវទាំងអស់ យល់រឿងរ៉ាវទាំងអស់ ហើយដូច្នេះខ្ញុំអាចកែប្រែសភាពការណ៍បានទាំងអស់ ។ តើទាំងអស់គ្នាយល់ថា ខ្ញុំមិនបានព្យាយាមរកយល់ឬ តើទាំងអស់គ្នាពិតជាយល់ឃើញថា នេះជាអ្វីដែលខ្ញុំចង់បានសម្រាប់ប្រជាជនរបស់ខ្ញុំឬ? កាលពីនៅយុវវ័យ ខ្ញុំបានខិតខំទៅតាមលទ្ធភាព និងមធ្យោបាយរបស់ខ្ញុំក្នុងគោលបំណងចង់កែប្រែរបបអយុត្តិធម៌ ។ ក្រោយមកខ្ញុំក៏បង្ខំចិត្តរត់គេខ្លួន ។ ខ្ញុំបានរួចជីវិតដោយសារតែខ្ញុំរត់ចូលព្រៃ ។ បន្ទាប់មកទៀត នៅពេលដែលខ្ញុំគិតថាមានមនុស្សដែលគេអាចបំពេញកិច្ចការបានល្អប្រសើរជាងខ្ញុំ ដើម្បីផលប្រយោជន៍ប្រជាជន និងជាតិរបស់ខ្ញុំ ខ្ញុំក៏ប្រាថ្នាចង់ឲ្យអ្នកទាំងនោះទទួលបានជ័យជម្នះ ហើយខ្ញុំក៏បានផ្តល់ដល់ពួកគេនូវការឧបត្ថម្ភតិចតួចស្តួចស្តើងតាមលទ្ធភាពដែលខ្ញុំអាចធ្វើទៅបាន ។
ពីព្រោះខ្ញុំជឿជាក់ទៅលើគម្រោងបដិវត្តន៍របស់គេនោះថា នឹងនាំឲ្យសង្គមបានប្រសើរជាងមុន ជាតិខ្ញុំបានរស់គង់វង្ស ទោះបើប្រទេសខ្ញុំត្រូវទទួលរងគ្រោះដោយសង្គ្រាមមហាវិនាសកម្ម ហើយត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទី រហូតដល់នាំឲ្យមានគ្រោះអាសន្ន ទុរ្ភិក្សថែមទៀតផងក៏ដោយ ។ ផ្ទុយស្រឡះពីការដែលបានលើកឡើងនៅក្នុងសវនាការនេះ ខ្ញុំមិនដែលបានចូលរួមធ្វើផែនការដែលនាំបង្កឲ្យមានទុក្ខវេទនាទាល់តែសោះ ។ គឺមិនដែលទាល់តែសោះ! មិនដែលទាល់តែសោះ! ដូចដែលខ្ញុំបានព្យាយាមនិយាយជម្រាបទៅដើមបណ្តឹងរដ្ឋប្បវេណីដែលបានឡើងមកនិយាយនៅក្នុងសវនាការនេះដូច្នោះដែរ គឺថាខ្ញុំមិនដែលគិតថា ចង់ឲ្យរឿងទាំងនោះកើតឡើងទាល់តែសោះ ។

នេះជារឿងតែមួយគត់ដែលខ្ញុំអាចនិយាយនៅថ្ងៃនេះ ពីព្រោះវាជាការពិត ប៉ុន្តែគ្មានអ្នកណាចង់ស្តាប់ខ្ញុំឡើយ ។ នៅចំពោះមុខការមិនរវល់អើពើដល់ការខិតខំពន្យល់របស់ខ្ញុំ ចំពោះមុខលក្ខខណ្ឌដំណើរការនៃតុលាការនេះ ខ្ញុំមានអារម្មណ៍ថា ទោះបីខ្ញុំខំនិយាយពន្យល់យ៉ាងណាក៏ដោយ ក៏គេនៅតែមិនយកចិត្តទុកដាក់ស្តាប់ខ្ញុំឡើយ ។ ផ្ទុយទៅវិញ ខ្ញុំមានអារម្មណ៍ថា ពេលណាខ្ញុំនិយាយ គេរឹតតែចងកំហឹងនឹងខ្ញុំកាន់តែខ្លាំងទៅទៀត ។ ដូច្នេះ ខ្ញុំគិតថាខ្ញុំមិនបាច់ឆោតល្ងង់ទៅនិយាយពន្យល់អ្នកដែលមិនចង់ស្តាប់ខ្ញុំនោះទេ ។ ខ្លួនខ្ញុំក៏ខ្ញុំសោកស្តាយណាស់ដែរ ដោយខំជឿយ៉ាងខ្លាំងពីដំបូង ថាតុលាការនេះអាចជាឱកាសសម្រាប់រូបខ្ញុំក្នុងការពន្យល់ ។ ក៏ប៉ុន្តែគ្រប់គ្នាចង់បានតែម្យ៉ាងគត់ពីខ្ញុំ គឺការសារភាពសុទ្ធសាធទៅតាមអ្វីដែលគេចោទមកលើខ្ញុំ ។ ឯការចោទប្រកាន់នោះទៀតក៏ជាការចោទប្រកាន់លើអំពើដែលខ្ញុំមិនបានប្រព្រឹត្តទាល់តែសោះ ។ ដោយហេតុថា ខ្ញុំមិនបានដឹងព្រឹត្តិការណ៍ដែលកើតឡើងជាបន្តបន្ទាប់ណាមួយ ខ្ញុំគ្មានហេតុផលអ្វីទៅលុនតួចំពោះការបងដាច់ណាត់មកលើខ្ញុំនោះដែរ ។ ខ្ញុំយល់ថា ការនៅស្ងៀមមិននិយាយស្តីរបស់ខ្ញុំ វាស្របនឹងកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្ញុំជាង ។ ហើយខ្ញុំទុកលទ្ធភាពជូនអស់លោក លោកស្រីចៅក្រមវិនិច្ឆ័យរូបខ្ញុំទៅចុះ ។ មេធាវីទាំងអស់របស់ខ្ញុំ និងក្រុមការងាររបស់ខ្ញុំបានការពារយ៉ាងមុតមាំ យ៉ាងខ្លាំងក្លា និងប្រកបដោយការជឿជាក់ ។ ហើយខ្ញុំសូមអរគុណដល់អ្នក

ទាំងអស់គ្នា ទោះបីលទ្ធផលវាទៅជាយ៉ាងណាក៏ដោយ ។ ខ្ញុំសង្ឃឹមជឿជាក់ថា ទោះជាយ៉ាងណាក្តី អស់លោក លោកស្រីនឹងស្វែងរកយុត្តិធម៌ ។ សូមអរគុណ ។

## ប្រធានជំនុំជម្រះ ណុន ប្រកាសបញ្ចប់សេចក្តីសន្និដ្ឋាននិងការរំពឹងទុកតទៅមុខទៀត

វេលាម៉ោង ២:១០នាទីរសៀល ប្រធានអង្គជំនុំជម្រះ ណុន ធ្វើការប្រកាសបិទបញ្ចប់ការស្តាប់និងការធ្វើសេចក្តីសន្និដ្ឋាន "ឥឡូវនេះ ដំណើរការនីតិវិធីសវនាការស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីលើសំណុំរឿង០០២/០១ នៃសំណុំរឿង០០២ បានចប់សព្វគ្រប់អស់ហើយ" ។ លោកប្រធានអង្គជំនុំជម្រះធ្វើការសរុបសេចក្តីសំណុំរឿង០០២/០១ ដូចតទៅ:

- អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដំណើរការសវនាការជំនុំជម្រះលើអង្គសេចក្តីពិនិត្យភស្តុតាងលើសំណុំរឿង០០២/០១ ដែលជាផ្នែកដំបូងនៃសំណុំរឿង០០២ ដែលមានជនជាប់ចោទចំនួនពីររូប ១) ឈ្មោះ នួន ជា, ២) ឈ្មោះ ខៀវ សំផន ដែលត្រូវជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។
- ដំណើរការសវនាការពិភាក្សាដេញដោល ពិនិត្យភស្តុតាងបានចាប់ផ្តើមពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ចំណាយពេលអស់២១២ថ្ងៃ និងសវនាការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីចាប់ផ្តើមពីថ្ងៃទី ១៦ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ដែលចំណាយពេលវេលាអស់១០ថ្ងៃ ។ គិតមកដល់នឹងពេលនេះកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្តីលើសំណុំរឿង០០២/០១ បានប្រព្រឹត្តទៅអស់រយៈពេលសរុប២២២ថ្ងៃ ។
- គិតចាប់តាំងពីពេលចាប់ផ្តើមសវនាការដេញដោយលើភស្តុតាង រហូតមកទល់នឹងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០១នេះ មានបុគ្គលចំនួន៩២រូប ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដែលក្នុងនោះរួមមាន អ្នកជំនាញចំនួនបីរូប សាក្សីចំនួន៥៧រូប ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣២រូប ។ បន្ថែមលើនេះមានវេជ្ជបណ្ឌិតព្យាបាលចំនួនពីររូប និងអ្នកជំនាញវេជ្ជសាស្ត្រចំនួនពីររូប បានផ្តល់សក្ខីកម្មទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទផងដែរ ។
- នៅក្នុងអំឡុងពេលធ្វើសវនាការលើសំណុំរឿង០០២/០១ ភាគីនានាបានប្តឹងសុំជាលាយលក្ខណ៍អក្សរចំនួនជាង២៩០បណ្តឹង ហើយជាលទ្ធផលគឺមានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងសេចក្តីសម្រេចផ្ទាល់មាត់ជាង២៥០សេចក្តីសម្រេច ដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូង ។

- ឯកសារចំនួនជាង៤០០០ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកជាភស្តុតាង នៅក្នុងសំណុំរឿង០០២/០១ ដែលសរុបទាំងអស់មានចំនួន ប្រមាណ១៦៦.៥០០ទំព័រ ដែលមានបីភាសា ។

ប្រធានអង្គជំនុំជម្រះ ណុន បង្ហាញពីការស្នើសុំរបស់ភាគីនានា ក្នុងការលើកយកឯកសារសម្ភារៈជាច្រើន ដើម្បីជាភស្តុតាង នៅក្នុងដំណើរការនីតិវិធី ។ គាត់បានលើកយក ទម្រង់ឯកសារផ្សេងៗជាច្រើន មកបង្ហាញ ។ ហើយនាពេលនេះ ដំណើរការសវនាការលើអង្គសេចក្តីចំពោះសំណុំរឿង ០០២/០១ ឃើញថាបានចប់សព្វគ្រប់ហើយ ។

មុននឹងប្រកាសបិទសវនាការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល លោក ណុន តំណាងឲ្យអង្គជំនុំជម្រះសាលាដំបូង សូមថ្លែងអំណរគុណចំពោះគ្រប់ភាគីទាំងអស់ដែលបានមកចូលរួមដំណើរការសំណុំរឿងនេះ ។ គាត់ក៏សូមថ្លែងអំណរគុណទៅដល់ សក្ខីជន និងការិយាល័យរដ្ឋបាល (ជាពិសេសអង្គភាពបកប្រែភាសា និងដោយឡែកចំពោះអ្នកបកប្រែភាសាផ្ទាល់មាត់) អង្គភាពចំណុះទាំងអស់ ។ គាត់ក៏ថ្លែងអំណរគុណដល់មន្ត្រី បុគ្គលិកមកពីស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ផ្នែកពន្លត់អគ្គីភ័យ ផ្នែកពេទ្យ និងផ្នែកដទៃទៀតដែលពាក់ព័ន្ធនឹងកិច្ចដំណើរការរបស់អង្គជំនុំជម្រះ ។ ចុងក្រោយ គាត់ថ្លែងអំណរគុណដល់ បុគ្គលិក មន្ត្រីមកពីអង្គការ និងមជ្ឈមណ្ឌលមួយចំនួនដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា (ឌី.ស៊ី.ខេម) ដែលបានជួយជ្រោមជ្រែងគាំទ្រដល់កិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០២/០១ អស់ពីកម្លាំងកាយចិត្តបញ្ញាស្មារតីតាំងពីថ្ងៃចាប់ផ្តើមដំបូងរហូតដល់ទីបញ្ចប់ប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលល្អប្រសើរ ។

លោក ណុន ប្រកាសថា "អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសបិទកិច្ចពិភាក្សាដេញដោលពិនិត្យភស្តុតាងលើសំណុំរឿងក្តី០០២/០១ ត្រឹមនេះ ហើយសូមប្រកាសជូនដល់ភាគី និងសាធារណជនបានជ្រាបថា បន្ទាប់ពីនេះទៅអង្គជំនុំជម្រះនឹងចាប់ផ្តើមនូវកិច្ចការថ្មីមួយទៀតរបស់ខ្លួន គឺការពិភាក្សាពិចារណាសម្រេចសេចក្តី និងរៀបចំនូវសាលក្រមវិនិច្ឆ័យលើសំណុំរឿងលេខ០០២/០១នេះ" ។ អង្គជំនុំជម្រះសាលាដំបូងមិនទាន់អាចកំណត់ជាក់លាក់បាននៅឡើយទេ ដោយហេតុថា "សំណុំរឿងក្តីនេះមានទ្រង់ទ្រាយធំធេង និងមានលក្ខណៈស្មុគស្មាញ ហើយនឹងត្រូវធ្វើការ ធ្វើជាបីភាសា ភាសាប្រើប្រាស់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ យើងនឹងជម្រាបជូនដំណឹងអំពីកាលបរិច្ឆេទ នៃសវនាការប្រកាសសាលក្រមដល់ភាគី និងសាធារណៈជនបានជ្រាបជាមុន ក្នុងកាលវេលាសមស្របមុនពេលប្រកាសសាលក្រម" ។

ទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីបំបែកសំណុំរឿង ប្រធានអង្គជំនុំជម្រះ ណុន លើកឡើងថា អង្គជំនុំជម្រះគ្រោងនឹងបើកកិច្ចប្រជុំរៀបចំសវនាការនៃសំណុំរឿង០០២/០២ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ដើម្បីពិនិត្យលើការរៀបចំការជំនុំជម្រះជាបន្តទៀតលើសំណុំរឿងលេខ ០០២/០២ ។

ទន្ទឹមគ្នានេះ អង្គជំនុំជម្រះសាលាដំបូង សម្រាបករណីសំណុំរឿង០០២/០១ ផ្អាកនៅវេលាម៉ោង២:២០នាទីរសៀល ។